**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីត្រៀមរៀបចំកិច្ចប្រជុំលើកទី២ រវាងអភិបាលខេត្តជាប់ព្រំដែន កម្ពុជា វៀតណាម

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង មួយដើម្បីរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែន កម្ពុជា វៀតណាម លើកទី ២ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម **វ៉ា គឹមហុង** | ប្រធានគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន | សមាជិក |
| ៤-ឯកឧត្តម **ទីយ រឿន** | អគ្គលេខាធិការរងរាជរដ្ឋាភិបាលកម្ពុជា | សមាជិក |

www.pheakdeylaw.com

៥- ឯកឧត្តម សត់ សេដ្ឋា អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិកអចិន្ត្រៃយ៍
៦-ឧត្តមសេនីយ៍ឯក ម៉ៅ ចំនួនតារា អគ្គស្នងការរងនគរបាលជាតិ សមាជិក
៧-ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ មេបញ្ជាការទីចាត់ការព្រំដែន
អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ សមាជិក
៨-ឯកឧត្តម ជាវ សាទី អ្នកបកប្រែភាសាវៀតណាម សមាជិក
៩-លោក ជាង ឡេងហួត អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក
១០-ឧត្តមសេនីយ៍ឯក ចាន់ អ៊ាន ប្រធាននាយកដ្ឋានកណ្តាលព្រំដែន អគ្គស្នងការនគរបាលជាតិ សមាជិក
១១-ឧត្តមសេនីយ៍ត្រី គៀត ចំនួនវឌ្ឍិ ប្រធាននាយកដ្ឋានជនបរទេស អគ្គស្នងការនគរបាលជាតិ សមាជិក
១២-ឧត្តមសេនីយ៍ត្រី វន ឈុនលី ប្រធាននាយកដ្ឋានព្រំដែនទឹក អគ្គស្នងការនគរបាលជាតិ សមាជិក
១៣-ឧត្តមសេនីយ៍ត្រី លីវ ម៉ូច ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ាន ក្រសួងមហាផ្ទៃ សមាជិក
១៤-តំណាងក្រសួងសុខាភិបាល សមាជិក
១៥-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
១៦-តំណាងក្រសួងធនធានទឹក និង ឧតុនិយម សមាជិក
១៧-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១៨-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក
១៩-តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
២០-តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
២១-តំណាងក្រសួងទេសចរណ៍ សមាជិក

**ប្រការ២ :** គណៈកម្មការនេះ មានភារកិច្ចពិភាក្សា សំរបសំរួលជាមួយក្រុមការងារវៀតណាម ដើម្បីរៀបចំកិច្ចប្រជុំលើកទី២ រវាងខេត្តជាប់ព្រំដែន កម្ពុជា វៀតណាម អោយដំណើរការបានលទ្ធផលល្អប្រសើរ ។

**ប្រការ៣ :** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងធនធានទឹក និង ឧតុនិយម និង ឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ ... ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ